# រឿងរាមកេរ្តិ៍នៅវិហារវត្តដំណាក់

រាមកេរ្តិ៍ ជាទេពកថាបុរាណដ៏ល្បីរបស់ឥណ្ឌា ដែលបានជ្រាបចូលក្នុងសង្គមខ្មែរយ៉ាងហោចណាស់តាំងពីរវាងសតវត្សទី៦ឬទី៧មកម្ល៉េះ។[1] គេសង្កេតឃើញមានភស្តុតាងច្បាស់លេចឡើងទាំងក្នុងសិលាចារឹក បដិមា របាំ ចម្រៀង គំនូរ កំណាព្យ ជំនឿ និងក្បួនច្បាប់ផ្សេងៗជាច្រើន។ បើមើលតែត្រឹមផ្នែកសិល្បៈដាប់ចម្លាក់ គេឃើញមានរូបតួអង្គឬឈុតខ្លះក្នុងរឿងរាមកេរ្តិ៍នេះ ឆ្លាក់នៅលើផ្នែកផ្សេងៗនៃសំណង់ប្រាសាទនានា រាប់តាំងពីផ្តែ ហោជាង រហូតមានឆ្លាក់លើផ្ទៃជញ្ជាំងយ៉ាងវែងនៅប្រាសាទអង្គរវត្តផង។ ទាំងនេះពុំរាប់បញ្ចូលបដិមាផ្សេងដូចជា រូបព្រះរាមរកឃើញនៅអង្គរបុរីជាដើមផង។ ក្នុងសង្គមខ្មែរ ការនិយមយករឿងរាមកេរ្តិ៍ឆ្លាក់នៅលើផ្នែកផ្សេងៗនៃសំណង់របៀបនេះ ក៏ឃើញនៅតាមវិហារព្រះពុទ្ធសាសនា ដូចមាននៅវិហារវត្តដំណាក់ជាឧទាហរណ៍ស្រាប់។

វត្តដំណាក់ ស្ថិតនៅត្រើយខាងកើតស្ទឹងសៀមរាប។ វិហារវត្តនេះ សង់លើខឿនកម្ពស់ប្រហែល១ម៉ែត្រ មានជណ្តើរឡើងបួនទិស ខាងកើតមានទ្វារ៣ ខាងលិចមានទ្វារ២ បង្អួច១៤ (ជើង៧ ត្បូង៧) ជាប្រភេទវិហារបុរាណ ប្រក់ក្បឿងស្រកាលេញ ដំបូលពីរថ្នាក់ជហ្វា៤ និងពុំមានមណ្ឌបនៅផ្នែកខាងលើ។[2] ជញ្ជាំងវិហារសង់ពីឥដ្ឋ និងកំបោរបាយអរ ហើយផ្នែកខាងក្នុងមានសសរឈើ៨ជ្រុង ចំនួន១២ ដើម ទ្រគ្រឿងបង្គុំឈើនៅផ្នែកខាងលើ។ ផ្ទៃជញ្ជាំងខាងក្នុងពុំមានគំនូរ ឬក្បូរក្បាច់លម្អអ្វីបន្តិចឡើយ ពោលគឺជាផ្ទៃលាតលាបពណ៌លឿងស្រាល។ រីឯផ្នែកខាងលើជាពិតានឈើ ហើយផ្ទៃធ្នឹមលម្អដោយក្បាច់ពណ៌ទឹកមាស។ ដោយឡែកនៅលើផ្ទៃសន្ទឹកទ្វារ និងបង្អួច (ផ្នែកខាងក្រៅ) ទាំងអស់ លម្អដោយតួអង្គក្នុងរឿងរាមកេរ្តិ៍ លាបទឹកមាសយ៉ាងរស់រវើកគួរឲ្យកោតសរសើរ។

នៅលើសន្ទឹកទ្វារខាងកើត ត្រង់ទ្វារកណ្តាល គេឆ្លាក់បង្ហាញត្រង់ព្រះលក្ស្មណ៍ប្រយុទ្ធនឹងវិរុលមុខកុមារដែលកាឡាខ្លួនជាឥន្ទ្រជិត។ ទ្វារឆ្វេងឆ្លាក់ត្រង់ព្រះលក្ស្មណ៍ត្រូវសរនាគបាស ហើយទ្វារស្តាំប្រហែលជាឆ្លាក់តួអង្គហនុមាន ប្រយុទ្ធនឹងឥន្ទ្រជិតក្នុងលំហ

[1] គង់ វីរៈ និង ព្រាប ចាន់ម៉ារ៉ា ២០១៤: ៨

[2] ព្រាប ចាន់ម៉ារ៉ា ២០១៧: ១៣-២៣, សុង សុភី ២០០៦: ១៤៩

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

មេឃ។ ចំណែកទ្វារខាងលិច លើទ្វារស្តាំគេឆ្លាក់រូបហនុមាននិងនាងបុញ្ញកាយ ហើយនៅទ្វារឆ្វេង ប្រហែលជារូបនាងបុញ្ញកាយនិងក្រុងរាពណ៍ជាឪពុកមា។[៣] ដោយឡែកនៅលើសន្ទឹកបង្អួចទាំង១៤ គឺជាការឆ្លាក់បង្ហាញក្បួនទ័ពរបស់ព្រះលក្ស្មណ៍ និងឥន្ទ្រជិតចូលប្រយុទ្ធក្នុងសមរភូមិ។ នៅលើបង្អួចខាងជើង ទ័ពព្រះលក្ស្មណ៍ចេញពីឆ្វេង ទ័ពឥន្ទ្រជិតចេញពីស្តាំ។ រីឯបង្អួចខាងត្បូង ទ័ពព្រះលក្ស្មណ៍ចេញពីស្តាំ ទ័ពឥន្ទ្រជិតចេញពីឆ្វេង ហើយចូលជួបទល់ទ័ពប្រយុទ្ធចំត្រង់បង្អួចកណ្តាលដូចគ្នា។ ផ្អែកលើទិដ្ឋភាព និងតួអង្គសំខាន់ៗខាងលើ គេដឹងថាជាសាច់រឿងរាមកេរ្តិ៍ត្រង់អន្ទើចម្បាំងឥន្ទ្រជិត។ សាច់រឿងអន្ទើនេះផ្តើមពីក្រុងរាពណ៍បង្គាប់ឲ្យនាងបុញ្ញកាយកាឡា ខ្លួនជាខ្មោចនាងសីតាអណ្តែតទឹក។ ឃើញដូច្នោះ ព្រះរាមក៏ប្រើហនុមានស្រង់សពនោះទៅបូជា ទើបដឹងថានាងបុញ្ញកាយកាឡាខ្លួន។ បន្ទាប់មក ហនុមានបានជូនបុញ្ញកាយត្រឡប់ទៅក្រុងលង្ការវិញ ហើយសង្គ្រាមក៏កើតឡើង។ សង្គ្រាមរវាងព្រះលក្ស្មណ៍និងឥន្ទ្រជិត សឹងប្រកបដោយយុទ្ធវិធីនិងកលល្បិចរៀងៗខ្លួន។ ទីបំផុត ព្រះរាមបានចូលផ្ទៃងសរផ្តាច់ក្បាលឥន្ទ្រជិតស្លាប់ទៅ។[៤]

តាមការសិក្សារបស់ *Daniel Guéret* និង *Doninique-Pierre Guéret* សន្និដ្ឋានថាវិហារនេះសង់នៅចុងសតវត្សទី១៩ ហើយសូមបញ្ជាក់ថានៅវិហារវត្តរាជបូព៌ ស្ថិតនៅខាងកើតវត្តដំណាក់ ក៏មានគំនូរបុរាណរឿងរាមកេរ្តិ៍។ វិហារនោះ សង់ក្នុងរវាងដើមសតវត្សទី២០។[៥] ទន្ទឹមនឹងនេះគេចាំបានថា កាលពីទសវត្ស១៩៦០ ក្រុមល្ខោនស្បែកធំនៃវត្តស្វាយដង្គុំក្នុងខេត្តសៀមរាបនេះ បានផ្សាយឥទ្ធិពលរបស់ខ្លួនចូលដល់សាលារចនា ហើយបើពិនិត្យឲ្យល្អិត ការដាប់ឆ្លាក់រូបតួអង្គនីមួយៗលើផ្ទាំងស្បែកទាំងនោះប្រកបដោយលក្ខណៈសិល្បៈនិងក្បាច់រចនាតួអង្គនីមួយៗ ស្ទើរដូចគ្នាទាំងស្រុងនឹងតួអង្គឆ្លាក់នៅលើសន្ទឹកទ្វារបង្អួចវត្តដំណាក់ និងទម្រង់គំនូរបុរាណនៅវត្តរាជបូព៌។ ដូច្នេះជារួមមក គំនូរ ចម្លាក់ និងស្បែកធំក្នុងតំបន់នេះ ហាក់មានលក្ខណៈសិល្បៈឆ្លើយឆ្លងគ្នាយ៉ាងពិសេសគួរឲ្យពិចារណា៕

---

[៣] នាងបុញ្ញកាយជាកូនរបស់ពិភេក ដែលជាប្អូនរបស់ក្រុងរាពណ៍។

[៤] ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ២០២០: ៤៥-៤៦

[៥] *Daniel Guéret & Doninique-Pierre Guéret 2017: 142*

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

# បញ្ជីរូបភាព



រូបលេខ១ ព្រះវិហារមើលមើលពីជ្រុងអាគ្នេយ៍



រូបលេខ២ ផ្នែកខាងក្នុងព្រះវិហារ



រូបលេខ៣ សិម្ពលីគ្រុឌធាបធក់បំផ្លាញ
សរនាគបាសរបស់ឥន្ទ្រជិត (ទ្វារខាងកើត)



រូបលេខ៤ ព្រះលក្ស្មណ៍ប្រយុទ្ធនឹងវិរុលមុខកុមារ
ដែលកាឡាខ្លួនជាឥន្ទ្រជិត (ទ្វារខាងកើត)

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត



រូបលេខ២៥ ព្រះលក្ខណ៍ផ្ទែងសរពាន់ប៉ង់សម្លាប់ឥន្ទ្រជិត (បង្អួចខាងជើង)



រូបលេខ២៦ ក្រុងរាពណ៍



រូបលេខ២៧ ទ័ពយក្ស



រូបលេខ២៨ ហនុមាន និងបុញ្ញកាយ



រូបលេខ២៩ ស្វាពលជិះក្ងោក

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

# ឯកសារយោង

ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ

២០២១. *ស្បែកធំ អន្ទើចម្លាំងឥន្ទ្រជិត*, ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ, ភ្នំពេញ

គង់ វីរៈ និង ព្រាប ចាន់ម៉ារ៉ា

២០១៤. *ស្បែកធំ*, យូណេស្កូ, ភ្នំពេញ

ព្រាប ចាន់ម៉ារ៉ា

២០១៧. *សំណង់នៅតាមវត្ត*, ភ្នំពេញ

សុង សុភី

២០០៦. "ការរចនាលំអ និងនៃស្ថាបត្យកម្មព្រះវិហារអំពីឈើ៖ ការបែងចែកផ្នែកទាំងឡាយទៅតាមប្រភេទ", *សំណង់អំពីឈើនៅប្រទេសកម្ពុជា៖ កេរដំណែលដែលកំពុងសាបសូន្យ*, មជ្ឈមណ្ឌលខេមរសិក្សា, ភ្នំពេញ

Daniel Guéret & Doninique-Pierre Guéret

2017, *The Khmer Pagoda,* Kam editions

AMS
អរិយធម៌ខ្មែរ
KHMER CIVILIZATION

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត